**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តព្រៃវែង**

# សន្និសីទសារព័ត៌មាន
# ស្តីពីវឌ្ឍនភាពការងារ របស់ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់
# ដោយ ឯកឧត្តម សៀង សារ៉ាត ប្រធានក្រុមប្រឹក្សាខេត្តព្រៃវែង

**ទីកន្លែង៖** ទីស្តីការគណៈរដ្ឋមន្ត្រី សាលសេរីភាព ជាន់ផ្ទាល់ដី
ថ្ងៃ**អង្គារ៍ ១២រោច** ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១

- សូមក្រាបថ្វាយបង្គំ **សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ សម្តេចព្រះសង្ឃនាយក សម្តេចព្រះសង្ឃនាយករង ព្រះសង្ឃគ្រប់ព្រះអង្គ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ !
- សូមគោរព **ឯកឧត្តម ផៃ ស៊ីផាន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា និងសហការី** ជាទីគោរព!
- សូមគោរព **ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា មន្ត្រីរាជការ និងអ្នកសារព័ត៌មានទាំងអស់** ជាទីគោរពរាប់អាន !
- សូមគោរពជម្រាបសួរ **លោកតា លោកយាយ អ៊ុំ ពូ មីង បងប្អូនប្រជាពលរដ្ឋ និងទស្សនិកជនទាំងអស់ ដែលកំពុងទស្សនាការផ្សាយផ្ទាល់ពិសេស** ជាទីគោរពស្រលាញ់ដ៏ជ្រាលជ្រៅបំផុត !

ថ្ងៃនេះ ក្នុងនាមរដ្ឋបាលខេត្តព្រៃវែង ខ្ញុំបាទ ពិតជាមានក្តីសោមនស្សរីករាយឥតឧបមា និងសូមថ្លែងអំណរគុណ ចំពោះអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា ដែលបានរៀបចំសន្និសីទសារព័ត៌មានរបស់**ក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់** និងសូមថ្លែងអំណរគុណដល់បងប្អូន អ្នកសារព័ត៌មាននៅទីនេះ ក៏ដូចជាបងប្អូនប្រជាពលរដ្ឋ ដែលបានតាមដានទស្សនាសន្និសីទសារព័ត៌មានតាមរយៈការ Live ផ្ទាល់តាមប្រព័ន្ធ Internet និងផ្សាយបន្តផ្ទាល់តាមកញ្ចក់ទូរទស្សន៍ នាពេលនេះ។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋខេត្តព្រៃវែងទាំងមូល ខ្ញុំបាទ សូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ដែលបានលះបង់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី បូជាសាច់ស្រស់ ឈាមស្រស់ រំដោះប្រជាជនឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ប៉ុលពត កសាង និងអភិវឌ្ឍប្រទេសជាតិ បង្កើតទំព័រសករាជថ្មី ជាពិសេសបានធ្វើឱ្យប្រទេសជាតិមានសុខសន្តិភាពពេញលេញ ប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ទោះបីជាប្រទេសកម្ពុជាយើង ធ្លាប់បានឆ្លងកាត់គ្រប់ឧបសគ្គ និងទទួលការគៀបសង្កត់ពីបណ្តាប្រទេសមហាអំណាចធំៗ

យ៉ាងណាក៏ដោយ ក៏ថ្នាក់ដឹកនាំកំពូលនៃព្រះរាជាណាចក្រកម្ពុជា ដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខ** នៅតែមានជំហររឹងមាំមិនចុះញ៉ម ប្រកាន់ខ្ជាប់នូវជំនឿជឿជាក់ មិនឱ្យបរទេសណាជ្រៀតជ្រែកដែនអធិបតេយ្យភាព គឺការមិនជ្រៀតចូលកិច្ចការផ្ទៃក្នុង របស់ប្រទេសខ្លួនបានឡើយ ដូចជារឿងការកាត់ផ្តាច់ប្រព័ន្ធអនុគ្រោះពន្ធEBAជាដើម...។ ប្រជាពលរដ្ឋកម្ពុជា សូម **អរគុណសន្តិភាព** និងមានមោទនភាពបំផុត ក្រោមការដឹកនាំដ៏ប៉ិនប្រសព្វ ឈ្លាសវៃ របស់ប្រមុខរាជរដ្ឋាភិបាល ជាពិសេសប្រជាពលរដ្ឋបានប្រសិទ្ធនាមជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី** ប្រទេសដ៏តូចមែនពិតតែមាន "**បេះដូងមនុស្សធម៌ធំជាងមហាសមុទ្រ**" ក្នុងការប្រយុទ្ធប្រឆាំងជំងឺរាតត្បាតជាសកល COVID-19 នឹងកាន់តែធ្វើឱ្យពិភពលោកទទួលស្គាល់នូវតម្លៃគុណធម៌ដ៏មហិមា របស់ **សម្តេចតេជោ** ជាថ្នាក់ដឹកនាំដែល "**មានបេះដូងមនុស្សធម៌មិនរើសអើង**" ដូចសុភាសិតខ្មែរពោលថា៖ **ចេះជួយគ្នាក្នុងគ្រាក្រស្គាល់មិត្តល្អក្នុងគ្រាលំបាក** ។

ឆ្លៀតក្នុងឱកាសនេះផងដែរ អនុញ្ញាតឱ្យខ្ញុំព្រះករុណា-ខ្ញុំបាទ សូមគោរពរាយការណ៍ជូន **សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី** អំពីស្ថានភាពទូទៅ និងវឌ្ឍនភាពការងារ របស់ក្រុមប្រឹក្សាខេត្តព្រៃវែង សម្រេចបានក្នុងឆ្នាំ២០២០ មានដូចតទៅ ៖

## I-អំពីស្ថានភាពទូទៅ របស់ខេត្តព្រៃវែង

ខេត្តព្រៃវែង ស្ថិតនៅប៉ែកអាគ្នេយ៍នៃប្រទេសកម្ពុជា ទីរួមខេត្តមានចំងាយ៩៥គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ (តាមផ្លូវជាតិលេខ១ ប្រវែង៦៥គីឡូម៉ែត្រ និងផ្លូវជាតិលេខ១១ ប្រវែង៣០គីឡូម៉ែត្រ) និងចំងាយ១០០គីឡូម៉ែត្រ តាមផ្លូវជាតិលេខ៨។ ខេត្តមានព្រំប្រទល់ខាងជើងទល់ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ខាងត្បូងទល់នឹងប្រទេសវៀតណាម ខាងកើតទល់នឹងខេត្តស្វាយរៀង និងប្រទេសវៀតណាម ខាងលិចទល់នឹងខេត្តកណ្តាល។ ខេត្តមានស្រុកចំនួន**១២** ក្រុងចំនួន**០១** ឃុំចំនួន**១១២** សង្កាត់ចំនួន**០៤** និងមានភូមិ**១.១៤៩** មានប្រជាពលរដ្ឋសរុប**១.២៤៩.៨១៣**នាក់ ស្រីចំនួន**៦៤៥.២៧០**នាក់ ស្មើនឹង**២៩០.១០៥** គ្រួសារ ក្នុងនោះ ប្រជាពលរដ្ឋ ដែលមានអាយុចាប់ពី**១៨**ឆ្នាំឡើងទៅ មានចំនួន**៨០០.៥៥៩**នាក់ ស្រីចំនួន**៤២២.០២៩**នាក់។ ខេត្តមានផ្ទៃដីសរុប**៤.៨៨៣**គីឡូម៉ែត្រក្រឡា និងមានដង់ស៊ីតេប្រជាជន**២៥៥**នាក់/គម²។ ខេត្តព្រៃវែង មានប្រជាពលរដ្ឋប្រកបរបរកសិកម្មជាចម្បងចំនួន**៦៣,៩%** សិប្បកម្មមានចំនួន**០,២%** សេវាកម្មមាន**៣៥,៩%** ក្នុងនោះ អត្រាប្រាក់ចំណូលជាមធ្យមប្រចាំឆ្នាំ របស់ប្រជាពលរដ្ឋមានចំនួន**១.២១៨,៩** ដុល្លា ដែលធ្វើឱ្យអត្រានៃភាពក្រីក្រ របស់ប្រជាពលរដ្ឋថយចុះមកនៅត្រឹម**៧,៤០%**។ ខេត្តមានច្រកទ្វារព្រំដែនចំនួន**០៦** ក្នុងនោះ មានច្រកទ្វារអន្តរជាតិចំនួន**០៣**កន្លែង គឺច្រកទ្វារព្រំដែនអន្តរជាតិបន្ទាយចក្រី កោះរការ ម៉ឺនជ័យ និងច្រកទ្វារតំបន់ព្រំដែនចំនួន**០៣**កន្លែង គឺច្រកទ្វារតំបន់ព្រំដែនកោះសំពៅ ពាមមន្ទារ ស្វាយអាដោង។

ខេត្តព្រៃវែង ជាខេត្តដែលមានសក្តានុពលផ្នែកកសិកម្ម មានផ្ទៃដីបង្កបង្កើនផលសរុបចំនួន**៣២៥.០០០**ហិកតា ក្នុងនោះ ផ្ទៃដីស្រូវវស្សាអនុវត្តបាន**២៨០.៣៩៩**ហិកតា ស្មើនឹង**១១២,១៦%**នៃផែនការ**២៥០.០០០**ហិកតា លើសឆ្នាំមុនចំនួន**៩.៨៥៥**ហិកតា និងទទួលបានទិន្នផលជាមធ្យម**៣.២៤០** គីឡូក្រាម/ហិកតា ដែលមានបរិមាណផលសរុប**៩០៨.៩៣៧**តោន និងស្រូវប្រាំងអនុវត្តបានលើផ្ទៃដី

**៧១.៩៨៥**ហិកតា ស្មើនឹង**៩៥%** នៃផ្ទៃដីគ្រោង**៧៥.០០០**ហិកតា ទិន្នផលជាមធ្យមបាន**៤.៤៨៣** គីឡូក្រាម/ហិកតា ព្រៃវែងជាខេត្ត ទទួលបានចំណាត់ថ្នាក់លេខ១ទូទាំងប្រទេសក្នុងការផលិតស្រូវ ជាប់គ្នា ២ឆ្នាំ គឺឆ្នាំ២០១៩ និងឆ្នាំ២០២០។ ប្រជាជនមានការសប្បាយរីករាយ ដោយតម្លៃស្រូវបច្ចុប្បន្ននេះ មានតម្លៃល្អចន្លោះពី**៩០០៛** ទៅ**១២០០៛**/គីឡូក្រាម។ ក្រៅពីដំណាំស្រូវ ខេត្តព្រៃវែងមានដំណាំរួមផ្សំជាច្រើន ដូចជាៈ ពោត សណ្តែក ល្ង អំពៅ ឈូក បន្លែ និងការ ចញ្ចឹមសត្វ គោ ក្របី ជ្រូក មាន់ទា ចញ្ចឹមត្រី បង្កង កង្កែប។ល។ ក្នុងនោះ វិស័យសំខាន់ៗដែលលេចធ្លោ នៃកិច្ចអភិវឌ្ឍខេត្ត រួមមាន វិស័យធនធានទឹក ធារាសាស្ត្រ សាធារណការដឹកជញ្ជូន អភិវឌ្ឍន៍ជនបទ រៀបចំដែនដី សុខាភិបាល អប់រំ សាសនា សេដ្ឋកិច្ច ហិរញ្ញវត្ថុ ពន្ធដារ ធនាគារ អគ្គិសនី ឧស្សាហកម្ម ទេសចរណ៍... ក៏បានខិតខំអនុវត្ត ទៅតាមតួនាទី ភារកិច្ច របស់ខ្លួនសម្រេចបានលទ្ធផលល្អប្រសើរ។ ចំពោះការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈទូទាំងខេត្ត សមត្ថកិច្ចគ្រប់ផ្នែក បានទប់ស្កាត់ទាន់ពេលវេលានូវរាល់សកម្មភាពជនអគតិមួយចំនួន និងរក្សាបាននូវសណ្តាប់ធ្នាប់សាធារណៈតាមទីប្រជុំជន និងរក្សាបាននូវស្ថេរភាពនយោបាយ និងសុខក្សេមក្សាន្តជូនប្រជាពលរដ្ឋ។

ខេត្តព្រៃវែង ជាខេត្តស្ថិតនៅតំបន់វាលទំនាបទន្លេមេគង្គ ដែលអំណោយផលដល់ចរាចរណ៍ដឹកជញ្ជូនតាមផ្លូវទឹក ដោយមានទន្លេមេគង្គ និងមានទន្លេតូចពីរខ្សែទៀត ក្នុងការដឹកជញ្ជូនកសិផលប្រជាពលរដ្ឋ ហើយមានផ្លូវគោកចំនួនបីខ្សែតភ្ជាប់ទៅព្រំដែនវៀតណាម។

ក្រុមប្រឹក្សាខេត្ត ដឹកនាំដោយ ប្រធាន**០១**រូប និងមានសមាជិកចំនួន**២៦**រូប ស្រីចំនួន**០៥**រូប។ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក សរុបចំនួន**២៤៩**រូប ស្រីចំនួន**៣៤**រូប និងក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន**៨៩២**រូប ស្រីចំនួន**១៦៥**រូប។

គណៈអភិបាលខេត្ត ដឹកនាំដោយ អភិបាល**០១**រូប និងមានអភិបាលរងចំនួន**០៦**រូប ស្រីចំនួន**០១**រូប។

ផ្អែកតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តិនានា ថ្នាក់ដឹកនាំរដ្ឋបាលខេត្តព្រៃវែង មានចក្ខុវិស័យច្បាស់លាស់ ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ដែលធ្វើឱ្យប្រជាពលរដ្ឋរស់នៅបានសុខសាន្ត មានជីវភាពធូធារ តាមរយៈកិច្ចការសំខាន់ៗដូចជា ការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងការដឹកនាំ ការអនុវត្តន៍តួនាទីភារកិច្ច ស្របតាមជំនាញ និងបទពិសោធន៍ ការផ្លាស់ប្តូរទស្សនៈ ឥរិយាបថរបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៅក្រោមឱវាទ ដែលឈានទៅរកការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍន៍ប្រកបដោយសមធម៌ និងចីរភាព។

## II- **វឌ្ឍនភាពការងារ របស់ក្រុមប្រឹក្សាខេត្ត**

- ក្រុមប្រឹក្សាខេត្ត បានបើកកិច្ចប្រជុំជាទៀងទាត់ស្របតាមប្រតិទិននៃកិច្ចប្រជុំសាមញ្ញ និងអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ដោយសង្កេតឃើញថា ពីកិច្ចប្រជុំមួយទៅកិច្ចប្រជុំមួយមានការរីកចម្រើនលើការពិភាក្សាយ៉ាងផុលផុស អំពីវឌ្ឍនភាពរបស់រដ្ឋបាលខេត្ត តាមការត្រួតពិនិត្យលើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ និងការឆ្លើយបំភ្លឺជូនអង្គប្រជុំពីបណ្តាមន្ទីរ អង្គភាពជំនាញ និងអ្នកពាក់ព័ន្ធប្រកបដោយការទទួលខុសត្រូវ។

- ក្រុមប្រឹក្សាខេត្ត អាណត្តិទី៣ បានប្រជុំសាមញ្ញរបស់ខ្លួនបានចំនួន**២០**លើក និងប្រជុំវិសាមញ្ញចំនួន**០៤**លើក។
- ក្រុមប្រឹក្សាខេត្ត បានរៀបចំបែងចែកការទទួលខុសត្រូវ លើកិច្ចប្រតិបត្តិការ ដែលជួយសម្រួលដល់ការបំពេញតួនាទី ភារកិច្ច របស់ខ្លួនសម្រាប់ការចុះទៅមូលដ្ឋាន។
- ក្រុមប្រឹក្សាខេត្ត បានទទួលការបណ្តុះបណ្តាលជាបន្តបន្ទាប់ ហើយបានធ្វើឱ្យសមាជិកក្រុមប្រឹក្សាមានការយល់ដឹង អំពីតួនាទី ភារកិច្ច របស់ខ្លួនបានល្អប្រសើរ និងបានចូលរួមសកម្មភាពនានាដូចជា សកម្មភាពសង្គម សកម្មភាពផ្នែកសាសនា សកម្មភាពកាអភិវឌ្ឍន៍ ជាមួយថ្នាក់ដឹកនាំខេត្ត និងបានចែករំលែកព័ត៌មាននានាដល់សមាជិកទាំងអស់ក្នុងជួរក្រុមប្រឹក្សា។
- បានរៀបចំបង្កើតគណៈកម្មការបោះឆ្នោតជ្រើសរើស ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋថ្នាក់ខេត្ត ស្របតាមខ្លឹមសារអនុក្រឹត្យលេខ១៩អនក្រ.បក របស់រាជរដ្ឋាភិបាលកម្ពុជា និងគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ។
- ក្រុមប្រឹក្សាបានទំនាក់ទំនង ជាមួយគណៈអភិបាល មន្ទីរ អង្គភាពជំនាញ មានភាពរលូន និងល្អប្រសើរ ដោយបានអញ្ជើញ ឱ្យចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាខេត្ត យ៉ាងទៀងទាត់ ដើម្បីរាយការណ៍។
- ការគ្រោងថវិកាប្រចាំឆ្នាំ ត្រូវបានពិភាក្សាក្នុងក្រុមការងារ ដែលមានតំណាងក្រុមប្រឹក្សាចូលរួម និងបានជជែកដេញដោល ដើម្បីសម្រេចទៅលើថវិកាគុណប្រយោជន៍ខេត្ត ឱ្យចំគោលដៅប្រកបដោយសមធម៌ រួចដាក់ជូនអង្គប្រជុំក្រុមប្រឹក្សាខេត្ត ដើម្បីសុំការអនុម័ត។
- បានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ របស់ក្រុមប្រឹក្សាខេត្តប្រចាំឆ្នាំនីមួយៗតាមកាលកំណត់ បានចេញដីកា ស្តីពីការបែងចែកសមាសភាពក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត សម្រាប់ដឹកនាំដំណើរការវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ប្រចាំឆ្នាំ**២០២០** របស់ខ្លួនចំនួន**០៦**ក្រុម ចុះតាមបណ្តាក្រុង ស្រុក ដែលមានអ្នកចូលរួមចំនួន**២.២៤៨**នាក់ ស្រី**៣៥០**នាក់ ឆ្លងតាមវេទិកាខាងលើនេះ យើងប្រមូលបាននូវបញ្ហាប្រឈម និងសំណូមពរនានាបានចំនួន**១៦៩**ករណី ក្នុងនោះបានដោះស្រាយរួចចំនួន៩៩ករណី បន្តដោះស្រាយចំនួន**៦៧**ករណី និងបញ្ជូន**០៣**ករណីទៅថ្នាក់ជាតិ ដើម្បីដោះស្រាយតាមនីតិវិធី។
- អនុម័តផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ(២០២០-២០២៤) ដែលជាចក្ខុវិស័យអភិវឌ្ឍខេត្ត ក្នុងអាណត្តិក្រុមប្រឹក្សា និងពិនិត្យ ផ្តល់យោបល់ អនុម័ត កម្មវិធីវិនិយោគ៣ឆ្នាំរំកិលខេត្ត(២០២០-២០២២) របស់រដ្ឋបាលខេត្ត។
- គាំទ្រមណ្ឌលអភិវឌ្ឍធនធានមនុស្ស ផ្អែកតាមផែនការ អន្តរាគមន៍អភិវឌ្ឍសមត្ថភាពស្ថាប័នខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ក្នុងរយៈពេលពេញមួយឆ្នាំក្រុមបច្ចេកទេស បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការស៊ីវិល នៅថ្នាក់ក្រោមជាតិ សរុបមានចំនួន០៣វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន**៧៩៣**នាក់ ស្រី**៣១៦**នាក់។

- គាំទ្រការរៀបចំ និងអនុវត្តគម្រោងខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ឆ្នាំ២០២០មាន៖ រដ្ឋបាលខេត្ត មានចំនួន**២១**គម្រោង រដ្ឋបាលក្រុង ស្រុក មានចំនួន**៣៦**គម្រោង រដ្ឋបាលឃុំ សង្កាត់មានចំនួន **១៤៧**គម្រោង និងមានគម្រោងដៃគូរអភិវឌ្ឍ(ADB)មានចំនួន**០៦**គម្រោង។
- ក្រុមប្រឹក្សាខេត្ត រួមជាមួយសប្បុរសជននានាបានសាងសង់ផ្ទះជូនប្រជាពលរដ្ឋក្រីក្រចំនួន០៧ខ្នង។

ក្រៅពីនេះ ក្រុមប្រឹក្សាខេត្ត បានចូលរួមយ៉ាងសកម្ម ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺ COVID-19 តាមរយៈការចុះសួរសុខទុក្ខប្រជាពលរដ្ឋ ដែលបានធ្វើចត្តាឡីស័កតាមមណ្ឌល ដែលខេត្តបានកំណត់ និងបានចូលរួមបរិច្ចាកជាថវិកាចំនួន**៥.១០០.០០០**រៀល ជូនដល់គណៈកម្មការCOVID-19ខេត្ត ដោយឡែកក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ បានចូលរួមបរិច្ចាកថវិកាចំនួន**៤៤.៩៩៤.០០០**រៀល និង**១១.០៤០**ដុល្លារ ជូន **សម្តេចតេជោ** ដើម្បីទិញវ៉ាក់សាំងចាក់ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ។ ផ្អែកលើមូលដ្ឋាននៃការរីករាលដាលនៃជំងឺCOVID-19នេះ បានធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋក្នុងខេត្ត ក្នុងនោះរាជរដ្ឋាភិបាលបានឧបត្ថម្ភជាសាច់ប្រាក់ ជូនដល់គ្រួសារក្រីក្រចំនួន **៦០.៣៩៨គ្រួសារ** អស់សាច់ប្រាក់ចំនួន**៧២.៧៨៨.៥៤៤.០០០**រៀល(ចិតសិបពីរពាន់ ប្រាំពីររយប៉ែតសិបប្រាំបីលាន ប្រាំរយសែសិបបួនពាន់រៀលគត់) និងបានឧបត្ថម្ភជាសាច់ប្រាក់ជូន ដល់ស្ត្រីមានផ្ទៃពោះ ចំនួន**៣.២៨២**នាក់ និងកុមារអាយុក្រោម**២**ឆ្នាំចំនួន**១.៤៣៦**នាក់ អស់សាច់ប្រាក់**១.៦៨០.០៨០.០០០**រៀល (មួយពាន់ ប្រាំមួយរយប៉ែតសិបលាន ប៉ែតសិបពាន់រៀល) និងក្នុងព្រឹត្តិការណ៍ថ្ងៃទី**២៨ វិច្ឆិកា** រាជរដ្ឋាភិបាល ក៏បានផ្តល់ថវិកាចំនួន**៥០.០០០.០០០**រៀល ដល់ប្រជាពលរដ្ឋក្រីក្រ ក្នុងខេត្តព្រៃវែង ដែលបានធ្វើចត្តាឡីស័ក រយៈពេល១៤ថ្ងៃ។ គិតត្រឹមថ្ងៃទី**០៧** ខែ**កុម្ភៈ** ឆ្នាំ**២០២១** ប្រជាពលរដ្ឋសង្ស័យ ដែលបានយកសំណាក ទៅពិនិត្យរកមេរោគCOVID-19 នៅវិទ្យាស្ថានប៉ាស្ទ័រ និងវិទ្យាស្ថានជាតិសុខភាពសាធារណៈបានចំនួន **៤.៥៥១**នាក់ ស្រី**១.៦៣៣**នាក់ ជាលទ្ធផលអវិជ្ជមានទាំងអស់។

## III-ទិសដៅការងារ របស់ក្រុមប្រឹក្សាខេត្ត

១-ក្រុមប្រឹក្សាខេត្ត បន្តរៀបចំកិច្ចប្រជុំសាមញ្ញ វិសាមញ្ញ តាមប្រតិទិន និងបន្តរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ របស់ក្រុមប្រឹក្សាខេត្តប្រចាំឆ្នាំ និងរៀបចំផែនការចុះគាំទ្រនៅមូលដ្ឋាន ដើម្បីប្រមូលយកតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តន៍មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា។

២-បន្តការគាំទ្រអនុវត្តមុខងារ ដែលបានប្រគល់ដោយក្រសួងស្ថាប័នថ្នាក់ជាតិ ដល់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់។

៣-ជំរុញ និងគាំទ្រ ការអនុវត្តន៍ក្របខ័ណ្ឌការងារគណនេយ្យភាពសង្គម និងយន្តការច្រកចេញចូលតែមួយ ដើម្បីបង្កើតសេវាសាធារណៈឱ្យកៀកនិងប្រជាពលរដ្ឋនៅមូលដ្ឋានប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

៤-បន្តពង្រឹងគោលនយោបាយរៀបចំផែនការអភិវឌ្ឍ និងកសាងកម្មវិធីវិនិយោគ ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ឱ្យស្របតាមតម្រូវការក្នុងការអភិវឌ្ឍន៍ខេត្ត។

៥-បន្តពិនិត្យ ផ្តល់យោបល់ និងអនុម័ត កម្មវិធីវិនិយោគ៣ឆ្នាំរំកិលខេត្ត និងការរៀបចំយុទ្ធសាស្ត្រថវិកា ឱ្យបានល្អប្រសើរ និងជោគជ័យ ដើម្បីឆ្លើយតបតាមតម្រូវការប្រជាពលរដ្ឋនៅមូលដ្ឋាន។
៦-ពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា ឱ្យស្របតាមលិខិតបទដ្ឋានគតិយុត្តិនានា និងបែងចែកភារកិច្ចចូលរួមគាំទ្រការងារ រាល់ការចេញសេចក្តីសម្រេច របស់អង្គប្រជុំក្រុមប្រឹក្សា។
៧-បន្តការខិតខំ និងគាំទ្រយន្តការសម្រុះសម្រួល និងដោះស្រាយវិវាទផ្សេងៗ ក្រៅប្រព័ន្ធតុលាការ និងតាមរយៈការិយាល័យប្រជាពលរដ្ឋ។
៨-ពង្រឹងទំនាក់ទំនង សាមគ្គីភាពឯកភាពផ្ទៃក្នុង សហការរួមគ្នាអនុវត្តការងារ តាមប្រព័ន្ធរដ្ឋបាលឯកភាព រវាងក្រុមប្រឹក្សា និងគណៈអភិបាល ធ្វើយ៉ាងណាឱ្យរដ្ឋបាលខេត្តមានការអភិវឌ្ឍន៍ជឿនលឿន តាមគោលនយោបាយ របស់រាជរដ្ឋាភិបាល។
៩-ជំរុញ រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ បន្តយកចិត្តទុកដាក់អនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ពិសេសទប់ស្កាត់ការចែកចាយ ការប្រើប្រាស់គ្រឿងញៀន បទល្មើសនានា ការជួញដូរមនុស្ស ល្បែងស៊ីសង និងរក្សាឱ្យបាននូវសុខសុវត្ថិភាពជូនប្រជាពលរដ្ឋ។ បន្តគាំទ្រ និងជំរុញការទប់ស្កាត់ការរីករាលដាលជំងឺCOVID-19 របស់គណៈកម្មការCOVID-19ខេត្ត ដោយចូលរួមក្នុងការផ្សព្វផ្សាយនូវវិធានការ របស់រាជរដ្ឋាភិបាល និងរបស់ក្រសួងសុខាភិបាល ពិសេសអនុវត្តឱ្យបាននូវប្រសាសន៍លើកឡើង របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** គឺ "បីការពារ និងបីកុំ"។

## IV-យន្តការនៃការអនុវត្តន៍ការងារក្រុមប្រឹក្សាខេត្ត ក្នុងការជម្រុញ និងគាំទ្រដើម្បីប្រសិទ្ធភាពការងារ របស់មូលដ្ឋានឃុំ-សង្កាត់

ដើម្បីឱ្យការអនុវត្តន៍ការងារមានប្រសិទ្ធភាព គុណភាព បរិយាប័ន ក្នុងការគាំទ្រមូលដ្ឋានឃុំ សង្កាត់ រដ្ឋបាលខេត្ត បានអនុវត្តតាមអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ចទំនាក់ទំនងការងាររបស់ ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក។ ក្នុងនោះក្រុមប្រឹក្សាខេត្តបានរៀបចំយន្តមួយចំនួនដូចខាងក្រោម៖

- ក្រុមប្រឹក្សាខេត្ត រួមជាមួយក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក បានទំនាក់ទំនង ពិភាក្សាពិគ្រោះយោបល់ ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ទូទាំងខេត្ត ក្នុងគោលបំណងឆ្លើយតបតម្រូវការចាំបាច់ របស់ប្រជាពលរដ្ឋ ក្នុងមូលដ្ឋានឃុំ សង្កាត់។
- គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក មេឃុំ ចៅសង្កាត់ មានភារកិច្ចអនុវត្តកិច្ចការប្រចាំថ្ងៃ ក្នុងការទំនាក់ទំនងគ្នាទៅវិញទៅមក រវាងខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ក្នុងនាមក្រុមប្រឹក្សាខេត្ត។
- ក្នុងការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការខាងលើនេះ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងខេត្ត ត្រូវមានភាពទទួលខុសត្រូវលើបីចំណុចៈ
    ក/-ផ្តល់យោបល់ ពិគ្រោះយោបល់ ត្រួតពិនិត្យ និងឆ្លើយតបទៅនឹងសេចក្តីត្រូវការ របស់ប្រជាពលរដ្ឋនៅមូលដ្ឋានទាំងអស់ក្នុងខេត្ត។

ខ/-លើកសំណូមពរដល់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក អំពីតម្រូវការនានារបស់ប្រជាពលរដ្ឋដែលក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់មិនអាចដោះស្រាយបាន។

គ/-ធ្វើសហប្រតិបត្តិការឱ្យបានពេញលេញ ជាមួយក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្នុងការលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍន៍នៅមូលដ្ឋានឱ្យបានទាន់ពេលវេលា និងល្អប្រសើរ។

- ក្រុមប្រឹក្សាខេត្ត ត្រូវបំពេញតួនាទីខាងលើនេះ លើមូលដ្ឋាននៃការធានាស្វ័យភាព របស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ស្របតាមគោលការណ៍នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ អនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្តនានា ។
- អភិបាលក្នុងនាមគណៈអភិបាលខេត្ត និងក្រុមប្រឹក្សាខេត្ត ជាអ្នកចុះហត្ថលេខា លើលិខិតបទដ្ឋានផ្សេងៗ ដើម្បីបម្រើឱ្យទំនាក់ទំនងការងារនានា។
- ក្រុមប្រឹក្សាខេត្ត ត្រូវបានទទួលប្រតិភូកម្មពីរាជរដ្ឋាភិបាល ដើម្បីផ្តល់ការគាំទ្រ និងសម្របសម្រួលធ្វើសហប្រតិបត្តិការ ជាមួយរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈម សំណូមពរចាំបាច់នានា របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងធ្វើឱ្យសម្រេចជោគជ័យនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល។
- ក្នុងការអនុវត្តន៍យន្តការ នៃការគាំទ្ររដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ក្រុមប្រឹក្សាខេត្តព្រៃវែង មានគណៈកម្មាធិការនានាចំនួន៥ ទីចាត់ការ-អង្គភាពចំនួន៩ ដើម្បីអនុវត្តការងារប្រចាំថ្ងៃ។

ជារួម ការលើកឡើងទាំងអស់ខាងលើ ដែលខ្ញុំបាទបានយកមកធ្វើបទបង្ហាញ ក្នុងកម្មវិធីសន្និសីទសារព័ត៌មាននាឱកាសនេះ គឺជាវឌ្ឍន៍ភាពការងាររបស់ក្រុមប្រឹក្សាខេត្ត និងយន្តការនៃការអនុវត្តន៍ការងារក្រុមប្រឹក្សាខេត្ត ក្នុងការជំរុញនិងគាំទ្រ ដើម្បីប្រសិទ្ធភាពការងាររបស់មូលដ្ឋានឃុំ-សង្កាត់នៃខេត្តព្រៃវែងយើងខ្ញុំ ដែលបានអនុវត្តកន្លងមក។

សារជាថ្មីម្តងទៀត ក្នុងនាមក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងប្រជាពលរដ្ឋទូទាំងខេត្ត និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សូមថ្លែងអំណរគុណដល់ឯកឧត្តម រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី ព្រមទាំងអ្នកសារព័ត៌មានទាំងអស់ ដែលបានចូលរួមក្នុងឱកាសនេះ។

ជាទីបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទសូមបួងសួងប្រសិទ្ធពរជ័យសិរីមង្គល វិបុលសុខគ្រប់ប្រការ និងសូមគោរពជូនពរ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រីក្នុងអង្គសន្និសីទ និងបងប្អូនប្រជាពលរដ្ឋទាំងអស់ សូមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរព្រះគុណ សូមអរគុណ**